ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# កំណត់ហេតុ

## ព្យួរកិច្ចសន្យាការងារ ក្រុមហ៊ុន ស៊ីលវើរ អេចធ៍ នីតធីង ឯ.ក

ឆ្នាំពីរពាន់ម្ភៃ ខែមេសារ ថ្ងៃទី២៤ មានការបើកកិច្ចប្រជុំនៅក្រុមហ៊ុន **ស៊ីលវើរ អេចធ៍ នីតធីង ឯ.ក** ដែលមានទីតាំង ស្ថិតនៅភូមិលេខ១ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល។
ក្រោមអធិបតីភាពលោក SHI KUNTIAN ជំនួសឲ្យនាយកក្រុមហ៊ុន និងលោកស្រី **ម៉ោញ ច័ន្ទកេសី** ប្រធានរដ្ឋបាល និងធនធានមនុស្ស បានពិនិត្យអំពីបញ្ហាក្រុមហ៊ុនជួបវិបត្តិហិរញ្ញវត្ថុ ព្រោះគ្មានភ្ញៀវបញ្ជាទិញ ដោយសារជំងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរ COVID-19 ។ ដូច្នេះហើយទើបក្រុមហ៊ុនឈានទៅដល់ការព្យួរកិច្ចសន្យាការងារកម្មករនិយោជិត ចំនួន ៣១៦ នាក់ ក្នុងនោះមានស្រីចំនួន ២២៥ នាក់ ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ៧៧៩ នាក់ ក្នុងនោះមានស្រីចំនួន ៥៨៤ នាក់។
នៅក្នុងអង្គប្រជុំនេះ លោក SHI KUNTIAN ជំនួសឲ្យនាយកក្រុមហ៊ុន បានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់ អំពីស្ថានភាពបច្ចុប្បន្ននៅក្នុងរោងចក្រថា ដោយសារតែជំងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរ COVID-19 ដែលធ្វើឲ្យក្រុមហ៊ុនយើងគ្មានភ្ញៀវបញ្ជាទិញ និងខ្វះសម្ភារវត្ថុធាតុដើមសម្រាប់ផលិត ដែលធ្វើឲ្យចង្វាក់ផលិតកម្មរបស់រោងចក្រទាំងមូលមិនអាចដំណើរការបាន។ ហេតុដូចនេះ ក្រុមហ៊ុនសម្រេចធ្វើការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតមួយចំនួន រយៈពេលចំនួន ១ ខែ គឺចាប់ពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២០។ នៅក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារនេះ កម្មករនិយោជិត បានឯកភាពទទួលយកនូវការផ្តល់ជូនរបស់ក្រុមហ៊ុននូវចំនួនទឹកប្រាក់ ៣០$ (សាមសិបដុល្លារសហរដ្ឋអាមេរិច) ក្នុង១ខែ សម្រាប់កម្មករនិយោជិតម្នាក់ៗ។

### សមាសភាពចូលរួម

**-តំណាងនិយោជក**

-លោក SHI KUNTIAN ជំនួសឲ្យនាយកក្រុមហ៊ុន
-លោកស្រី **ម៉ោញ ច័ន្ទកេសី** ប្រធានរដ្ឋបាល និងធនធានមនុស្ស

**-តំណាងកម្មករនិយោជិត**

-លោក **ណា ផានិត** ជាប្រធានសហជីពការពារកម្មករខ្មែរ នៃរោងចក្រតម្បាញ ស៊ីលវើរ អេចធ៍ នីតធីង ឯ.ក
-លោក **ណាំង សុខវី** ជាអនុប្រធានសហជីពការពារកម្មករខ្មែរ នៃរោងចក្រតម្បាញ ស៊ីលវើរ អេចធ៍ នីតធីង ឯ.ក
-លោកស្រី **សន គឹមនី** ជាលេខាធិការិកាសហជីពការពារកម្មករខ្មែរ នៃរោងចក្រតម្បាញ ស៊ីលវើរ អេចធ៍ នីតធីង ឯ.ក

លោក **ណា ផានិត** ជាប្រធានសហជីពការពារកម្មករខ្មែរ នៃរោងចក្រតម្បាញ ស៊ីលវើរ អេចធ៍ នីតធីង ឯ.ក មានប្រសាសន៍ថា ក្រុមហ៊ុនពិតជាគ្មានការងារធ្វើមែន ព្រោះគ្មានអ្នកបញ្ជាទិញ ដោយសារជំងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរ កូវីដ-១៩ ប្រាកដមែន។ ដូច្នេះ ខ្ញុំមិនជំទាស់ការព្យួរកិច្ចសន្យាការងារនេះទេ។
លោកស្រី **អ៊ុ សុភារម្យ** ជាតំណាងកម្មករ នៃក្រុមហ៊ុន ស៊ីលវើរ អេចធ៍ នីតធីង ឯ.ក មានប្រសាសន៍ថា ខ្ញុំឯកភាពលើការព្យួរកិច្ចនេះ ព្រោះក្រុមហ៊ុនពិតជាគ្មានការងារធ្វើប្រាកដមែន។

ប្រធានក្រុមគ្រប់ផ្នែកទាំងអស់ បានចូលរួមកិច្ចប្រជុំ ហើយបានឯកភាពទាំងអស់គ្នា រួចផ្តិតជាភស្តុតាង។

-លទ្ធផលពិភាក្សា

លោក SHI KUNTIAN ជំនួសឲ្យនាយកក្រុមហ៊ុន និងតំណាងកម្មករ ព្រមទាំងប្រធានសហជីពមូលដ្ឋាន បានឯកភាពគ្នាលើការព្យួរកិច្ចសន្យាការងារនេះ ព្រោះក្រុមហ៊ុនពិតជាគ្មានការងារធ្វើប្រាកដមែន។

កិច្ចប្រជុំបានចប់សព្វគ្រប់នៅវេលាម៉ោង ១៥ និង០០ នាទីព្រឹក ថ្ងៃខែឆ្នាំដដែល។

ធ្វើនៅខេត្តកណ្ដាល ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០

**ហត្ថលេខា ឬស្នាមមេដៃរបស់គូភាគី**

| ភាគីនិយោជក | សាក្សីដឹងលឺ | ភាគីតំណាងកម្មករនិយោជិត |
|---|---|---|
| ក្រុមហ៊ុន ស៊ីលវើរ អេចជ៍ និតធីង ឯ.ក SILVER AGE KNITTING CO., LTD. KINGDOM OF CAMBODIA<br>SHI KUNTIAN | | |